# មេរៀនទី 1:
# ការណែនាំពី Internet និង Email

**1. និយមន័យរបស់ Internet:**

Internet គឺជាពាក្យកាត់មកពីពាក្យ international Networking មានន័យថាគឺជាការភ្ជាប់ទំនាក់ទំនងគ្នារវាង computers យ៉ាងច្រើនទូទាំងពិភពលោក ដើម្បីធ្វើការផ្តល់ និងទទួលព័ត៌មានឬទិន្នន័យជាមួយគ្នាទៅវិញទៅមក។

Internet គឺជាកន្លែងប្រមូលផ្តុំនៃ Websites ជាច្រើន របស់ក្រុមហ៊ុន ឬស្ថាប័ននានា ដែលពួកវាត្រូវបានបង្កើត ឡើង ដើម្បីធ្វើការបង្ហាញពីព័ត៌មានមួយចំនួនដែលទាក់ទងទៅនឹង ក្រុមហ៊ុនឬស្ថាប័នទាំងអស់នោះ។

**2. ប្រវត្តនៃការបង្កើត Internet:**

Internet ត្រូវបានបង្កើតឡើដោយ U.S. Department of Defense Advanced Research Projects Agency (ARPA) មួយនៅក្នុងកំឡុងឆ្នាំ 1960 ។ រហូតមកដល់ឆ្នាំ 2010 មានអ្នកប្រើប្រាស់ Internet ប្រមាណចាប់ពី 1410 លាន ដល់ 1830 លាននាក់ ទូទាំងពិភពលោក ក្នុងនោះ ប្រជាជនកម្ពុជាមាន 78000 នាក់ផងដែរ។

**3. និយមន័យរបស់ Website:**

Website របស់ក្រុមហ៊ុន ឬស្ថាប័ននានា ដែលនៅក្នុង Internet គេប្រើសំរាប់ធ្វើការ ចូលទៅកាន់ក្រុមហ៊ុនឬស្ថាប័ន ទាំងនោះដើម្បីធ្វើការមើលព័ត៌មានផ្សេងៗ ហើយនៅក្នុងភាសាបច្ចេកទេស គេអាចហៅវាថា Domain ។ ដែលក្នុង នោះ Websites នីមួយៗត្រូវបានបង្កើតឡើងដោយ បណ្តុំនៃ Webpages ទាំងអស់បញ្ចូលគ្នាដែលមានដូចជា អក្សរ រូបភាព File ចំរៀង Video ឬ Programs របស់កម្មវិធីមួយចំនួនទៀត... ។

គ្រប់ Websites នីមួយៗតែងតែមាន address មួយៗដាច់ដោយឡែកពីគ្នាដែលគេហៅវាថា Uniform Resource Locator (URL) ឬភាសាសាមញ្ញគឺ address website ។

Ex:

www.yahoo.com

www.google.com

www.facebook.com

**4. សិក្សាពី URL:**



Protocol Prefix : គឺជា Protocol សំរាប់ប្រើប្រាស់នៅក្នុង Internet (http មកពីពាក្យ HyperText Transfer Protocol)។

Web service : គឺសំរាប់ប្រើប្រាស់ទូទៅនៅក្នុង Internet (www មកពីពាក្យ World Wide Web)។

Company name : គឺជាឈ្មោះរបស់ក្រុមហ៊ុន (Ex: yahoo, google,facebook, youtube,...)។

Domain name extension : គឺជាអក្សរកាត់ សំរាប់បញ្ជាក់ពី Business របស់ក្រុមហ៊ុន។

| Extension | Meaning |
|---|---|
| .biz | Business |
| .com (.co in UK) | Commercial |
| .edu (.ac in UK) | Educational and research |
| .gov | Government |
| .info | General use |
| .org | Non-profit organization |

Country code : គឺជាអក្សរកាត់របស់ប្រទេសដែលក្រុមហ៊ុនស្ថិតនៅ។

| Country code | Meaning |
|---|---|
| .kh | Cambodia |
| .kr | Korea |
| .th | Thailand |
| .cn | China |
| .uk | United Kingdom |
| .us | USA |

**5. និយមន័យ Web Page & Home Page:**

Web page គឺជាទំព័រនីមួយៗរបស់ Website ដែលវាមានន័យថា Web page ច្រើនបញ្ចូលគ្នាបង្កើតបានជា Website ។ Webpage នីមួយៗអាចមានទិន្នន័យដូចជា អក្សរ រូបភាព File ចំរៀង Video ឬ Programs របស់កម្មវិធីមួយចំនួនទៀត ។ Web page ដែលបង្ហាញឡើងមុនគេនៅពេលបើក website ណាមួយនោះ គេហៅវា ថាជា Home page ។

**6. និយមន័យ Email:**

Email (Electronic Mail) ន័យថាគឺជា សារ, Message, ឬព័ត៌មាន ដែលអាចផ្ញើរទៅគ្នាទៅវិញទៅមកតាមរយះប្រព័ន្ធ Internet ។ វាផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់អ្នកប្រើប្រាស់ ដូចជាផ្តល់និងទទួលព័ត៌មានពីគ្នាទៅវិញទៅមកបានក្នុងរយៈពេលលឿន និងអាចទំនាក់ទំនងបានទូទាំងពិភពលោក។ក្រុមហ៊ុនដែលផ្តល់សេវាកម្ម Email មានដូច ជា Yahoo, Gmail, Hotmail, Skype,... ។

**7. Search Engine:**

Search Engine គឺជាប្រភេទ Website ដែលត្រូវបានប្រើប្រាស់សំរាប់ធ្វើការស្វែងរក ស្រាវជ្រាវទៅតាមគោលបំណងរបស់អ្នកប្រើប្រាស់ ដោយមិនចាំបាច់ដឹងពី Address Website ណាមួយនោះទេ គឺគ្រាន់តែវាយអក្សរទៅក្នុងប្រអប់របស់ Website ប្រភេទជា Search Engine នោះវានឹងបង្ហាញពីលទ្ធផលយ៉ាងច្រើនសន្ធឹកសន្ធាប់មកវិញ។ Website ប្រភេទ Search Engine មានដូចជា

> www.google.com

> www.altavista.com

> www.bing.com

> www.dogpile.com

> www.hotbot.com

> www.lycos.com

> www.metacrawler.com

> www.netspape.com

> www.northernlight.com

## 8. Social Network:

Social Network គឺជាប្រភេទ Website ចអ្នកប្រើប្រាស់ធ្វើការភ្ជាប់ទំនាក់ទំនងគ្នាដោយអាច Send Message, រូបភាព, ឬ Files ផ្សេងៗចគ្នាទៅវិញទៅមក ហើយជាពិសេសអាចធ្វើការនិយាយឆ្លើយឆ្លងទល់មុខគ្នាបានទៀត ផង។ ប្រភេទ Website ជា Social Network មានដូចជា facebook ឬ Yahoo Messenger ដែលកំពុងពេញនិយម ក្នុងការប្រើប្រាស់ ហើយរួមទាំង Website មួយចំនួនទៀតដូចខាងក្រោម ៖

> www.twitter.com

> www.myspace.com

> www.hi5.com

> www.skype.com

## 9. អ្វីជា Web Browser:

Web Browser គឺជាកម្មវិធីសំរាប់ប្រើប្រាស់ដើម្បីធ្វើការបើក Website មានន័យថាដើម្បីបើក Website របស់ណា មួយ យើងត្រូវវាយ address website ឬ URL របស់វានៅក្នុង Web Browser។ Web Browser សព្វថ្ងៃមានជាច្រើន ដូចជា Internet Explorer, Mozilla Firefox, Opera, Safari,Chrome...។

ឧទាហរណ៍ខាងក្រោមនឹងបង្ហាញពីការបើក Website មួយគឺ www.google.com.kh ដោយប្រើប្រាស់ Web Browser ឈ្មោះ Internet Explorer ដូច្នេះសូមអនុវត្តដូចខាងក្រោម

1. សូមបើកកម្មវិធី Internet Explorer >




2. ក្នុងប្រអប់ URL Box សូមសរសេរ address website ដែលត្រូវការ (Ex: www.google.com.kh) >

3. ចុច Go to Button >

4. បន្ទាប់មកវានឹងបង្ហាញពី Website ដែលត្រូវការ




## 10. និយមន័យ Upload/Download:

Upload :មានន័យថាគឺជាការបញ្ជូនទិន្នន័យពីអ្នកប្រើប្រាស់ទៅកាន់ Web site។

Download :មានន័យថាគឺជាការទទួលទិន្នន័យពី Web site មកកាន់អ្នកប្រើប្រាស់ វិញ។

## 11. សំនួរ:

1. អ្វីទៅជា Website, Webpage, Home Page?
2. ដូចម្តេចដែលហៅថា URL?
3. ចូរធនិយមន័យ Search Engine និង Social Network?
4. ដូចម្តេចដែលហៅថា Browser?ចូររាប់ឈ្មោះ Browser ដែលបានសិក្សា?

មជ្ឈមណ្ឌលព័ត៌មានវិទ្យាអិនធ័រ www.enteritc.com